Network-Interface Controller (NIC) ក៏សំដៅទៅលើអាដាប់ទ័របណ្តាញ ឬអាដាប់ទ័រ LAN ភ្ជាប់ទៅបណ្តាញដោយប្រើខ្សែអ៊ីសឺរណិចមួយ។ NICs អាចជាកាតខាងក្នុងរួមបញ្ចូលទៅនឹងផ្ទាំងប្រព័ន្ធ ឬខាងក្រៅ (កាតបន្ថែម) ។ កុំព្យូទ័រថ្មីភាគច្រើនមានអាដាប់ទ័របណ្តាញ។

Wireless Local-Area Network adapter (អាដាប់ទ័របណ្តាញក្នុងតំបន់ឥតខ្សែ)

អាដាប់ទ័រ WLAN ប្រើបច្ចេកវិទ្យា WiFi និងអនុញ្ញាតឱ្យឧបករណ៍របស់អ្នកភ្ជាប់ទៅម៉ាតទ័រឥតខ្សែបាន។ កុំព្យូទ័ររបស់អ្នកមានអាដាប់ទ័រ WLAN ខាងក្នុង និងខាងក្រៅ (កាតបន្ថែម ឬបានឧបញ្ចូលក្នុងផ្ទាំងប្រព័ន្ធ)។

អាដាប់ទ័របណ្តាញតំបន់ធំទូលាយឥតខ្សែ

ឧបករណ៍បញ្ជាអាដាប់ទ័របណ្តាញតំបន់ធំទូលាយឥតខ្សែ (WWAN) អនុញ្ញាតឱ្យមានការភ្ជាប់ឥតខ្សែតាមរយៈបណ្តាញបច្ចេកវិទ្យា cellular tower (បច្ចេកវិទ្យាទូរស័ព្ទ)។ បច្ចេកវិទ្យានេះគឺមានជាពិសេសនៅលើទូរស័ព្ទ ថេប្លេត និងកុំព្យូទ័រយួរដៃរបស់អ្នកជំនួញ។ ស៊ីមកាត និងកិច្ចសន្យាសេវាកម្មមួយអាចតម្រូវឱ្យមាន ការភ្ជាប់ WWAN ។

ប៊ីជូស

ប៊ីជូសអនុញ្ញាតឱ្យអ្នកភ្ជាប់ឧបករណ៍ប៊ីជូសផ្សេងទៀតទៅនឹងកុំព្យូទ័រឬថេប្លេតរបស់អ្នកក្នុងរយៈពេលខ្លី។ ឧបករណ៍ប៊ីជូសអាចរាប់បញ្ចូលទាំងទូរស័ព្ទ កាស ក្តារចុច ឧបករណ៍ចុច ម៉ាស៊ីនបោះពុម្ពជាដើម។ អាដាប់ទ័រប៊ីជូសអាចនៅខាងក្នុង (កាតពង្រីក ឬបញ្ចូលទៅក្នុងផ្ទាំងប្រព័ន្ធ) ឬនៅខាងក្រៅ។

ម៉ាទ័រកាន់តែទំនើបដូចជាម៉ាទ័រសហគ្រាស ភ្ជាប់រាជីវកម្មធំៗ ឬ បណ្តាញ ISP ទៅកាន់ម៉ាទ័រដែលមានអនុគាតខ្ពស់ដែល បញ្ជូនទិន្នន័យនៅល្បឿនលឿនតាមខ្សែកាបអុបទិកនៃឆ្នេរខ្នងអ៊ិនធឺណិត។

Near-Field Communication (ទំនាក់ទំនងចម្ងាយជិត)

Near-Field Communication (NFC) អនុញ្ញាតឱ្យអ្នកប្តូរទិន្នន័យរវាងឧបករណ៍ពីរដោយប៉ះគ្នាទៅវិញទៅមក ឬដោយដាក់ពួកវាជិតគ្នា។ អ្នកអាចប្រើប្រាស់ឧបករណ៍ដែលមាន NFC ដើម្បីអានស្លាក NFC ធ្វើការទូទាត់ប្រាក់ ចែករំលែកឯកសារអាងឧបករណ៍ដែលត្រូវគ្នា និងផ្សេងៗទៀត។

នៅលើកុំព្យូទ័រយួរដៃ និងថេប្លេត Dell ដែលគាំទ្រ NFC គឺវាត្រូវបានបើកតាមលំនាំដើម នៅពេលដែលទំនាក់ទំនងឥតខ្សែត្រូវបានបើក។

ចំណាំ: សម្រាប់ការតភ្ជាប់ឧបករណ៍ដែលមាន NFC របស់អ្នកទៅកុំព្យូទ័រ ឬថេប្លេតរបស់អ្នក សូមមើលឯកសារឧបករណ៍របស់អ្នក។

ចំណាំ: សម្រាប់ការចែករំលែកការងារអាងឧបករណ៍ដែលប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Windows តែប៉ុណ្ណោះ។

3

ការប្រើប្រាស់កុំព្យូទ័ររបស់អ្នក

ការសាកថ្ម

តភ្ជាប់អាដាប់ទ័រថាមពលទៅកុំព្យូទ័រ ឬថេប្លេតរបស់អ្នកដើម្បីសាកថ្ម។

ថ្មត្រូវបានបញ្ចូល នៅពេលដែលកុំព្យូទ័រឬថេប្លេតកំពុងដំណើរការ ឬបិទ។ សៀគ្វីខាងក្នុងរបស់ថ្មការពារពីការសាកថ្មជ្រុល។

ចំណាំ: បើសិនជាថ្មមានកម្តៅក្តៅរោកដោយសារស្ថិតនៅក្នុងបរិស្ថានដែលក្តៅ វារមិនអាចនឹងមិនសាកថ្មទេ នៅពេលអ្នកតភ្ជាប់អាដាប់ទ័រ។

អនុញ្ញាតឲ្យថ្មចុះត្រជាក់ដើម្បីឲ្យវាបន្តសាកថ្ម។

ចំណាំ: សម្រាប់ជំហានផ្សេងៗដើម្បីធ្វើឲ្យអាយុកាលថ្មនៃកុំព្យូទ័ររបស់អ្នកកាន់តែប្រសើរ សូមមើល Improving battery life (ការធ្វើឲ្យអាយុកាលថ្មកាន់តែប្រសើរ)។

ប្រើប្រាស់ក្តារចុចរបស់អ្នក

ចុចគ្រាប់ចុចនៅលើក្តារចុចខាងក្រៅរបស់អ្នក ឬប៉ះតួអក្សរលើក្តារចុចនៅលើអក្រង់ដើម្បីវាយអត្ថបទ និងដើម្បីអនុវត្តមុខងារផ្សេងទៀត។

ផ្លូវកាត់ក្តារចុច

គ្រាប់ចុចខ្លះនៅលើក្តារចុចរបស់កុំព្យូទ័រឆ្លងដែន ឬនៅលើក្តារចុចខាងក្រៅ អាចមានមុខងារ ពីរ ឬលើសពីនេះនៅពេលចុចជាមួយគ្រាប់ចុចពិសេសណាមួយដូចជាគ្រាប់ចុច Fn ។ កុំព្យូទ័រខ្លះអាចឲ្យអ្នកប្រើសរើសលក្ខណៈលំនាំដើមនៃគ្រាប់ចុចដោយប្រើកម្មវិធីដំឡើង BIOS ឬការប្រើផ្លូវកាត់ក្តារចុច

តារាង 2. បញ្ជីផ្លូវកាត់ក្តារចុច

Ctrl, Shift និង Esc	បើកវីនដូ Task Manager។
Fn និង F8	ប៊ូតុងបិទបើករវាងឧបករណ៍អក្រង់—— សម្រាប់តែអក្រង់សំខាន់ប៉ុណ្ណោះ ស្ទួន បន្ថែមដល់អក្រង់ទាំងពីរ និងអក្រង់ទីពីរប៉ុណ្ណោះ។ កំណត់រូបតំណាងដែលអ្នកចង់បានដើម្បីត្រលប់ការបង្ហាញទៅជម្រើសនោះ។
Fn និងគ្រាប់ចុចសញ្ញាព្រួញឡើងលើ	ដំឡើងពន្លឺនៅលើអក្រង់ខាងក្នុងតែប៉ុណ្ណោះ (មិនមែនអក្រង់ដែលភ្ជាប់នៅខាងក្រៅឡើយ)។
Fn និងគ្រាប់ចុចសញ្ញាព្រួញចុះក្រោម	បន្ថយពន្លឺនៅលើអក្រង់ខាងក្នុងតែប៉ុណ្ណោះ (មិនមែនអក្រង់ដែលភ្ជាប់នៅខាងក្រៅឡើយ)។
Windows និងគ្រាប់ចុច L	ចាក់សោរប្រព័ន្ធ។
Fn និង Esc	បើកដំណើរការម៉ូឌុលគ្រប់គ្រងថាមពល។ អ្នកអាចម៉ៅបចំផ្លូវកាត់ក្តារចុចឡើងវិញដើម្បីបើកដំណើរការម៉ូឌុលគ្រប់គ្រងថាមពលខុសគ្នាដោយប្រើថេបកម្រិតខ្ពស់នៅក្នុងវីនដូ **Power Options Properties**។
F2	ប្តូរប្រឈ្មោះធាតុដែលបានជ្រើសរើស។
F3	ស្វែងរកឯកសារ ឬសឺមុ៊។
F4	បង្ហាញរបាររាសយដ្ឋានទម្លាក់ចុះនៅក្នុង Windows Explorer ។
F5	ធ្វើឲ្យធ្នាំងវីនដូសកម្មឡើងវិញ។
F6	ក្រឡេងតាមរយៈធាតុអក្រង់ក្នុងវីនដូ ឬនៅលើផ្ទៃកុំព្យូទ័រ។
F10	បើកដំណើរការបារម៉ឺនុយក្នុងកម្មវិធីសកម្ម។
Ctrl និង c	ចម្លងធាតុដែលបានជ្រើសរើស។
Ctrl និង x	កាត់ធាតុដែលបានជ្រើសរើស។
Ctrl និង V	បិទភ្ជាប់ធាតុដែលបានជ្រើសរើស។
Ctrl និង Z	មិនធ្វើសកម្មភាពវិញ។

តារាង 2. បញ្ជីផ្លូវកាត់ក្តារចុច (បានបន្ត)

Ctrl និង A	ជ្រើសរើសធាតុទាំងអស់ក្នុងឯកសារ ឬវិនដូ។
Ctrl និង F4	បិទវិនដូសកម្ម (នៅក្នុងកម្មវិធីដែលអនុញ្ញាតឱ្យអ្នកបើកឯកសារច្រើនក្នុងពេលដំណាលគ្នា)។
Ctrl, Alt និង Tab	ប្រើគ្រាប់ចុចសញ្ញាព្រួញដើម្បីផ្លាស់រវាងធាតុដែលបើក។
Alt និង Tab	ផ្លាស់រវាងកម្មវិធីដែលបើក។
Alt និង Esc	ក្រឡឹងតាមរយៈធាតុដែលត្រូវបានបើក។
លុប (Delete)	លុបធាតុដែលបានជ្រើសហើយផ្លាស់ទីវាទៅក្នុងធុងសម្រាម។
Shift និង Delete	លុបធាតុដែលបានជ្រើសដោយមិនចាំបាច់ផ្លាស់ទីទៅក្នុងធុងសំរាម។ **ប្រយ័ត្ន៖ ឯកសារដែលបានលុបដោយប្រើវិធីសាស្ត្រនេះមិនអាចយកមកវិញពីធុងសម្រាមបានទេ។**
Ctrl និងគ្រាប់ចុចព្រួញខាងស្តាំ	ផ្លាស់ទីទស្សន៍ទ្រនិចទៅដើមពាក្យបន្ទាប់។
Ctrl និងគ្រាប់ចុចព្រួញខាងឆ្វេង	ផ្លាស់ទីទស្សន៍ទ្រនិចទៅដើមពាក្យពីមុន។
Ctrl និងគ្រាប់ចុចព្រួញចុះក្រោម	ផ្លាស់ទីទស្សន៍ទ្រនិចទៅខាងដើមនៃកថាខណ្ឌបន្ទាប់។
Ctrl និងគ្រាប់ចុចព្រួញឡើងលើ	ផ្លាស់ទស្សន៍ទ្រនិចទៅដើមនៃកថាខណ្ឌពីមុន។
Ctrl, Shift ជាមួយគ្រាប់ចុចព្រួញ	ជ្រើសរើសប្លុកនៃអត្ថបទ។
Shift ជាមួយគ្រាប់ចុចព្រួញណាមួយ	ជ្រើសធាតុច្រើនជាងមួយក្នុងវិនដូ ឬនៅលើផ្ទៃកុំព្យូទ័រ ឬជ្រើសអត្ថបទក្នុងឯកសារណាមួយ។
គ្រាប់ចុច Windows និង m	ទម្លាក់វិនដូដែលបើកទាំងអស់ចុះក្រោម។
គ្រាប់ចុច Windows, Shift និង m	បើកវិនដូដែលបានទម្លាក់ចុះទាំងអស់ឡើងវិញ។ ការរួមបញ្ចូលជាមួយគ្រាប់ចុចនេះមានមុខងារក្នុងការក្រឡឹងវិនដូដែលបានទម្លាក់ចុះឡើងវិញ ដោយអនុវត្តតាមការប្រើប្រាស់គ្រាប់ចុច Windows និងការរួមបញ្ចូលគ្នាជាមួយ m។
គ្រាប់ចុច Windows និង e	ចាប់ផ្តើម កម្មវិធី Windows Explorer។
គ្រាប់ចុច Windows និង r	បើកប្រអប់ Run។
គ្រាប់ចុច Windows និង f	បើកប្រអប់ Search Results (លទ្ធផលស្វែងរក)
គ្រាប់ចុច Windows និង Ctrl និង f	បើកប្រអប់ Search Results-Computer (លទ្ធផលស្វែងរកកុំព្យូទ័រ) ប្រសិនបើកុំព្យូទ័រភ្ជាប់ទៅបណ្តាញ។
គ្រាប់ចុច Windows និង Pause (ផ្អាក)	បើកប្រអប់ System Properties ។

ផ្លូវកាត់ក្តារចុចសម្រាប់ Windows 8.1 និង Windows RT

តារាងនេះផ្តល់នូវផ្លូវកាត់ក្តារចុចមួយចំនួនជាពិសេសសម្រាប់ Windows 8.1 និង Windows RT។ ផ្លូវកាត់ក្តារចុចទាំងនេះ គឺបន្ថែមទៅលើផ្លូវកាត់ក្តារចុចដែលមានស្រាប់នៅលើ Windows ក៍ណាមុនៗ។

តារាង 3. បញ្ជីផ្លូវកាត់ក្តារចុច

គ្រាប់ចុច Windows និងចាប់ផ្តើមវាយបញ្ចូល	ស្វែងរកកុំព្យូទ័ររបស់អ្នក។
Ctrl និង +	ពង្រីកធាតុមួយចំនួនធំនៅលើអេក្រង់ ដូចជាកម្មវិធីដែលរោតជាប់នៅលើអេក្រង់ចាប់ផ្តើម។
Ctrl និង -	បង្រួមធាតុមួយចំនួនធំនៅលើអេក្រង់ ដូចជាកម្មវិធីដែលរោតជាប់នៅលើអេក្រង់ចាប់ផ្តើម។
គ្រាប់ចុច Windows និង c	បើករបាទំហៀងតាម។
គ្រាប់ចុច Windows និង f	បើកតាមស្វែងរក ដើម្បីស្វែងរកឯកសារនៅលើកុំព្យូទ័ររបស់អ្នក។
គ្រាប់ចុច Windows និង h	បើកតាមស្វែងរក។
គ្រាប់ចុច Windows និង i	បើកតាមការកំណត់។
គ្រាប់ចុច Windows និង j	ប្តូរវាងកម្មវិធីចម្បង និងកម្មវិធីដែលបានខ្ទាស់។
គ្រាប់ចុច Windows និង k	បើកតាមឧបករណ៍។
គ្រាប់ចុច Windows និង o	ចាក់សោទិសអេក្រង់ (បញ្ឈរ ឬផ្តេក)។

តារាង 3. បញ្ជីផ្លូវកាត់ក្តារចុច (បានបន្ត)

គ្រាប់ចុច Windows និង q	បើកឆាមស្វែងរក ដើម្បីស្វែងរកកម្មវិធីនៅលើកុំព្យូទ័ររបស់អ្នក។
គ្រាប់ចុច Windows និង w	បើកឆាមស្វែងរក ដើម្បីស្វែងរកការបញ្ជានៃការកំណត់កុំព្យូទ័រនៅលើកុំព្យូទ័ររបស់អ្នក។
គ្រាប់ចុច Windows និង z	បង្ហាញជម្រើសដែលមាននៅក្នុងកម្មវិធី។
គ្រាប់ចុច Windows និង របារដកឃ្លា	ប្តូរភាសាបញ្ចូល និងប្តង់ក្តារចុច។
គ្រាប់ចុច Windows, Ctrl និងរបារដកឃ្លា	ប្តូរទៅភាសាបញ្ចូល និងប្តង់ក្តារចុចដែលបានជ្រើសរើសពីមុន។
គ្រាប់ចុច Windows និង Tab	ក្រឡឹងផ្លូងកាត់កម្មវិធីដែលបើក ខណៈដែលបង្ហាញវានៅក្នុងរបារចំហៀងបញ្ឈរនៅខាងឆ្វេងនៃអេក្រង់។
គ្រាប់ចុច Windows, Ctrl និង Tab	បង្ហាញរបារចំហៀង ដើម្បីបើកកម្មវិធី ប្រើក្បារបារចំហៀងនៅលើអេក្រង់ ទោះបីបន្ទាប់ពីលែងចុចគ្រាប់ចុច។ នោះអ្នកអាចរុករកឆ្លងកាត់កម្មវិធីដែលបើក ដោយប្រើព្រាស់គ្រាប់ចុចសញ្ញាព្រួញឡើងលើ/ចុះក្រោម។
គ្រាប់ចុច Windows, ប្តូរ (Shift), និង .	ខ្ទាស់កម្មវិធីទៅខាងឆ្វេង។
គ្រាប់ចុច Windows និង .	ក្រឡឹងផ្លូងកាត់កម្មវិធីដែលបើក។

ចំណាំ: សម្រាប់គ្រាប់ចុចផ្លូវកាត់ពិសេសដែលមាននៅលើកុំព្យូទ័ររបស់អ្នក សូមមើល *Quick Start Guide (ការណែនាំទាប់ផ្តើមរហ័ស)*{ ដែលបានភ្ជាប់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ: www.dell.com/support ។

ប្តូរក្តារចុចរបស់អ្នកតាមបំណង

អ្នកអាចប្តូរក្តារចុចរបស់អ្នកតាមបំណងដូចខាងក្រោម៖

- ផ្លាស់ប្តូរពេលវេលាមុនពេលតួអក្សរលើក្តារចុចចេញម្តងទៀត នៅពេលដែលអ្នកចុចគ្រាប់ចុចជាប់
- ផ្លាស់ប្តូរល្បឿនដែលតួអក្សរលើក្តារចុចចេញម្តងទៀត
- ផ្លាស់ប្តូរអត្រាលោតភ្លឹបភ្លែតរបស់ទស្សន៍ទ្រនិច
- ប្តូរលំដាប់គ្រាប់ចុចតាមបំណងសម្រាប់ភាសាបញ្ចូល

ដើម្បីប្តូរក្តារចុចរបស់អ្នកតាមបំណង៖

Windows 10 និង 8.1

1. វាយបញ្ចូល **Control Panel (ផ្ទាំងបញ្ជា)** នៅក្នុងប្រអប់ស្វែងរក។
   ចំណាំ: នៅក្នុង Windows 10 សូមចុចឬប៉ះលើរូបតំណាងស្វែងរកដើម្បីចូលដំណើរការប្រអប់ស្វែងរក។ នៅក្នុង Windows 8.1 ចូលដំណើរការឆាម (charm) ស្វែងរកដើម្បីចូលដំណើរការប្រអប់ស្វែងរក។
2. ចុច **Control Panel**។
3. បើសិនជាផ្ទាំងបញ្ជារបស់អ្នកត្រូវបានបង្ហាញតាមប្រភេទ សូមចុចឬប៉ះលើពាក្យ **View by (មើលតាម)**៖ នៅក្នុងម៉ឺនុយធ្លាក់ចុះ រួចជ្រើសរើស**Small icons (រូបតំណាងតូច)** ឬ **Large icons (រូបតំណាងធំ)**។
4. ចុច ឬប៉ះលើពាក្យ **Keyboard (ក្តារចុច)**។
5. លៃតម្រូវការកំណត់ក្តារចុច ដែលអ្នកចង់ផ្លាស់ប្តូរ រួចចុចឬប៉ះលើ **OK (យល់ព្រម)** ដើម្បីរក្សាទុកការកំណត់ និងបិទវីនដូនោះ។

Windows 7

1. ចុច **Start (ចាប់ផ្តើម)** #menucascade-separator**Control Panel (ផ្ទាំងបញ្ជា)**។
2. បើសិនជា **Control Panel**របស់អ្នកត្រូវបានបង្ហាញតាមប្រភេទ សូមចុចឬប៉ះលើពាក្យ **View by (មើលតាម)**៖ នៅក្នុងម៉ឺនុយធ្លាក់ចុះ រួចជ្រើសរើស**Small icons (រូបតំណាងតូច)** ឬ **Large icons (រូបតំណាងធំ)**។
3. ចុច **Keyboard (ក្តារចុច)**។
4. លៃតម្រូវការកំណត់ក្តារចុច ដែលអ្នកចង់ផ្លាស់ប្តូរ រួចចុចលើ **OK (យល់ព្រម)** ដើម្បីរក្សាទុកការកំណត់ និងបិទផ្ទាំងនោះ។

ប្រើក្តារចុចលេខនៅលើកុំព្យូទ័រយួរដៃ



1. ក្តារចុចលេខ

កុំព្យូទ័រយួរដៃរបស់អ្នកអាចមានក្តារចុចលេខដែលមាននៅក្នុងក្តារចុចស្រាប់។ ក្តារនេះត្រូវគ្នានឹងក្តារចុចដែលបានបង្កប់មកដែរ។

- ដើម្បីវាយលេខ ឬនិមិត្តសញ្ញា ចុចឲ្យជាប់លើគ្រាប់ចុច Fn ហើយចុចគ្រាប់ចុចដែលអ្នកចង់ចុច។
- ដើម្បីបើកក្តារចុចលេខ ចុចលើគ្រាប់ចុច Num Lock ។ ពន្លឺរបស់គ្រាប់ចុច Num Lock បង្ហាញថាក្តារចុចលេខត្រូវបានដំណើរការ។
- ដើម្បីបិទក្តារចុចលេខ ចុចលើគ្រាប់ចុច Num Lock ម្តងទៀត។

ចំណាំ: កុំព្យូទ័រយួរដៃខ្លះមានក្តារចុចលេខដាច់តែម្តង។

ការប្រើប្រាស់បន្ទះប៉ះរបស់អ្នក

ប្រើប្រាស់បន្ទះប៉ះដើម្បីផ្លាស់ទីម៉ៅ ឬជ្រើសរើសវត្ថុនៅលើអេក្រង់។

- ដើម្បីផ្លាស់ទីម៉ៅ ចូរអំពិលម្រាមដៃរបស់អ្នកនៅលើបន្ទះប៉ះថ្មមៗ។
- ដើម្បីចុចឆ្វេង ឬជ្រើសរើសវត្ថុ សូមចុចប៊ូតុងបន្ទះប៉ះខាងឆ្វេង ឬចុចលើបន្ទះប៉ះម្តង។
- ដើម្បីចុចម៉ៅស្តាំលើវត្ថុ សូមចុចប៊ូតុងបន្ទះប៉ះខាងស្តាំម្តង។
- ដើម្បីចុចពីរដងលើវត្ថុ សូមចុចប៊ូតុងបន្ទះប៉ះពីរដង ឬចុចពីរដងលើបន្ទះប៉ះ។
- ដើម្បីប្រើសើស និងផ្លាស់ទី (ឬអូស) វត្ថុ ដាក់ម៉ៅលើវត្ថុ រួចចុចពីរដងឲ្យជឿនៅលើបន្ទះប៉ះដោយមិនដកម្រាមដៃរបស់អ្នកចេញពីបន្ទះប៉ះ បន្ទាប់ពីចុចលើកទីពីរ រួចផ្លាស់ទីវត្ថុដែលបានជ្រើសរើសដោយអំពិលម្រាមដៃរបស់អ្នកលើផ្ទៃបន្ទះប៉ះ។

កាយវិការលើបន្ទះប៉ះ

ចំណាំ: កាយវិការលើបន្ទះប៉ះមួយចំនួនអាចមិនដំណើរការនៅលើកុំព្យូទ័ររបស់អ្នកទេ។

ចំណាំ: អ្នកអាចផ្លាស់ប្តូរការកំណត់កាយវិការលើបន្ទះប៉ះ ដោយចុចទ្វេដងលើរូបតំណាងបន្ទះប៉ះនៅកន្លែងជូនដំណឹង។

កុំព្យូទ័ររបស់អ្នកអាចគាំទ្រកាយវិការ **Scroll (អូស)**, **Zoom (ពង្រីកបង្រួម)**, **Rotate (បង្វិល)**, **Flick (ផាត់ចេញ)**, និង **Quick Launch** ។

តារាង 4. បញ្ជីកាយវិការលើបន្ទះប៉ះ

អូស 	**វិញ** – ផ្លាស់ទីរោយផ្តោតទៅលើវត្ថុដែលបានជ្រើសរើសនៅពេលដែលវត្ថុទាំងមូលមិនអាចមើលឃើញ។ ផ្លាស់ទីម្រាមដៃរទៅទិសដែលចង់បាន ដើម្បីរុញរោយអូសលើវត្ថុដែលបានជ្រើស។

តារាង 4. បញ្ជីកាយវិការលើបន្ទះប៉ះ (បានបន្ត)

	ការអូសជួរឈរដោយស្វ័យប្រវត្តិ– អូសឡើងលើ ឬចុះក្រោមនៅលើផ្ទាំងវិនដូសកម្ម។ ផ្លាស់ទីម្រាមដៃពីរឡើងលើ ឬចុះក្រោមនៅល្បឿនល្បឿនដើម្បីចាប់ផ្តើមអូសជួរឈរដោយស្វ័យប្រវត្តិ។ ប៉ះលើបន្ទះប៉ះដើម្បីបញ្ឈប់ការអូសដោយស្វ័យប្រវត្តិ។
	ការអូសជួរដេកដោយស្វ័យប្រវត្តិ– អូសទៅឆ្វេង ឬស្តាំលើផ្ទាំងវិនដូសកម្ម។ ផ្លាស់ទីម្រាមដៃពីរទៅឆ្វេង ឬស្តាំឱ្យល្បឿនដើម្បីចាប់ផ្តើមអូសជួរដេកដោយស្វ័យប្រវត្តិ។ ប៉ះលើបន្ទះប៉ះដើម្បីបញ្ឈប់ការអូសដោយស្វ័យប្រវត្តិ។
	អូសជាអង្គំឡើងលើ/ចុះក្រោម —អូសឡើង ឬចុះ។ នៅក្នុងតំបន់អូសជួរឈរនៅគែមខាងស្តាំនៃបន្ទះប៉ះ សូមផ្លាស់ទីម្រាមដៃរបស់អ្នកតាមទ្រនិចនាឡិកាដើម្បីអូសឡើងលើ និងបញ្ច្រាសទ្រនិចនាឡិកាដើម្បីអូសចុះក្រោម។
	រូបភាព៖ អូសជាអង្គំទៅឆ្វេង/ស្តាំ — អូសទៅឆ្វេង ឬស្តាំ។ នៅក្នុងតំបន់អូសជួរឈរនៅគែមខាងស្តាំនៃបន្ទះប៉ះ សូមផ្លាស់ទីម្រាមដៃរបស់អ្នកតាមទ្រនិចនាឡិកាដើម្បីអូសទៅស្តាំ និងបញ្ច្រាសទ្រនិចនាឡិកាដើម្បីអូសទៅឆ្វេង។
ពង្រីកបង្រួម 	**ពង្រីកបង្រួមដោយម្រាមដៃមួយ**——ពង្រីក ឬបង្រួមដោយផ្លាស់ទីម្រាមដៃនៅក្នុងតំបន់ពង្រីកបង្រួម (នៅគែមឆ្វេងនៃបន្ទះប៉ះ) ។ អូសម្រាមដៃឡើងនៅក្នុងតំបន់ពង្រីកបង្រួមដើម្បីពង្រីក។
	អូសម្រាមដៃចុះក្រោមនៅក្នុងតំបន់ពង្រីកបង្រួមដើម្បីបង្រួម។
	រូបភាព៖ ពង្រីកបង្រួមដោយម្រាមដៃពីរ——ពង្រីក ឬបង្រួមដោយប្រើម្រាមដៃពីរ។ ដាក់ម្រាមដៃពីរនៅលើបន្ទះប៉ះ រួចផ្លាស់ទីម្រាមដៃចេញពីគ្នាដើម្បីពង្រីក។
	ដាក់ម្រាមដៃពីរនៅលើបន្ទះប៉ះ រួចទាញម្រាមដៃពីចូលគ្នាដើម្បីបង្រួម។
បង្វិល 	**ងួត**— បង្វិលមាតិកាសកម្មតាមមុំ 90 ដឺក្រេកើនឡើងដោយប្រើម្រាមដៃពីរ។ ដាក់ម្រាមដៃនៅខ្វែងគន្លឹះ ផ្លាស់ទីចង្កុលឯកតន្លះរង្វង់ទៅខាងស្តាំ ឬទៅឆ្វេងដើម្បីបង្វិលធាតុដែលបានជ្រើសរើស 90 ដឺក្រេតាមទ្រនិចនាឡិកា ឬបញ្ច្រាសទ្រនិចនាឡិកា។
ដាក់មកវិញ 	ត្រឡប់មាតិការទៅមុខ ឬថយក្រោយ។ ផ្លាស់ទីម្រាមដៃបីឱ្យល្បឿនទៅខាងឆ្វេង ឬស្តាំដើម្បីត្រលប់មាតិការទៅក្រោយ ឬទៅមុខ។
Quick Launch 	បើកកម្មវិធីចំណូលចិត្តរបស់អ្នក។ ដាក់ម្រាមដៃបីនៅលើបន្ទះប៉ះដើម្បីបើកដំណើរការកម្មវិធីដែលបានកំណត់រចនាសម្ព័ន្ធជាមុន។ **ចំណាំ:** ប្រើកម្មវិធីកំណត់រចនាសម្ព័ន្ធបន្ទះប៉ះដើម្បីជ្រើសរើសកម្មវិធីដែលនឹងត្រូវចាប់ផ្តើម។

ការប្រើអក្រង់ប៉ះរបស់អ្នក

ចំណាំ: ជៀសវាងការប្រើអក្រង់ប៉ះនៅក្នុងបរិស្ថានមានធូលី ក្តៅ ឬសើម។

ចំណាំ: ការប្រែប្រួលនៃសីតុណ្ហភាពខ្លាំងៗអាចបណ្តាលឱ្យមានកម្តៅនៅលើផ្ទៃខាងក្នុងនៃអក្រង់។ វាមិនប៉ះពាល់ដល់ការប្រើប្រាស់ធម្មតាទេហើយបាត់វិញបន្ទាប់ពីកុំព្យូទ័រត្រូវបានរក្សាទុកយ៉ាងហោចណាស់ 48 ម៉ោង។

ប្រសិនបើកុំព្យូទ័រ ឬថេប្លេតរបស់អ្នកមានអេក្រង់ប៉ះ អ្នកអាចប៉ះលើអេក្រង់ដើម្បីប៉ះលើធាតុណាមួយដោយមិនចាំបាច់ប្រើអ៊ីមែ ឬក្តារចុចឡើយ។ ភារកិច្ចសំខាន់ៗមួយចំនួនដែលអ្នកអាចអនុវត្តដោយប្រើអេក្រង់ប៉ះគឺបើកឯកសារ សឺម៉ុ និងកម្មវិធី ពង្រីក បង្រួម អូស និងបង្វិលរូបភាពជាដើម។

អ្នកអាចអនុវត្តបានជាធម្មតាដោយប្រើអ៊ីមែរួចជាបើកឯកសារ ចតដាក់ឯកសារ និងកម្មវិធីនានា អូសដោយប្រើរបារអូស បិទនិងបង្រួមវិនដូរដោយប្រើប៊ូតុងនៅលើវិនដូជាដើម។

អ្នកក៏អាចប្រើការចុចលើអេក្រង់ដោយប្រើអេក្រង់ប៉ះបានផងដែរ។

ការប៉ះលើអេក្រង់ប៉ះ

ការប៉ះលើអេក្រង់ប៉ះបង្កើនសមត្ថភាពប្រើប្រាស់អេក្រង់ប៉ះដោយអនុញ្ញាតឲ្យអ្នកធ្វើកិច្ចការរួចជាពង្រីកបង្រួម អូស បង្វិល និងផ្សេងៗ ដោយការអូស ឬចុចម្រាមដៃរបស់អ្នកនៅលើអេក្រង់។

ចំណាំ: ការប៉ះទាំងនេះមួយចំនួនគឺសំដៅទៅលើកម្មវិធីជាក់លាក់ហើយអាចនឹងមិនដំណើរការនៅក្នុងកម្មវិធីទាំងអស់ឡើយ។

តារាង 5. បញ្ជីនៃការវិការលើអេក្រង់ប៉ះ

ពង្រីកបង្រួម 	ដាក់ម្រាមដៃពីរនៅលើអេក្រង់ប៉ះហើយបន្ទាប់មកផ្លាស់ទីចេញគីគ្នាដើម្បីពង្រីក។
	ដាក់ម្រាមដៃពីរនៅលើអេក្រង់ប៉ះហើយបន្ទាប់មកអូសម្រាមទាំងពីរទៅជិតគ្នាដើម្បីបង្រួម។
ប៉ះ 	ប៉ះ និងសង្កត់ធាតុនៅលើអេក្រង់ដើម្បីបើកម៉ឺនុយខនិច ។
ផាត់ចេញ	ផ្លាស់ទីម្រាមដៃមួយឲ្យល្បឿនក្នុងទិសដៅដែលចង់បានដើម្បីអូសមាតិការនៅក្នុងវិនដូសកម្មដូចជាទំព័រនានាក្នុងសៀវភៅ។ Flick ក៏ដំណើរការបានដោយបញ្ឈរនៅពេលរុករក content ដូចជារូបភាព ឬបទចំម្រៀងនៅក្នុងបញ្ជីចាក់បទចម្រៀង។

តារាង 5. បញ្ជីនៃកាយវិការលើអក្រង់ប៉ះ (បានបន្ត)

	
បង្វិល 	**បង្វិលតាមទ្រនិចនាឡិកា**——ដាក់ម្រាមដៃ ឬមេដៃនៅកន្លែងដាក់ម្រាមដៃអូស ផ្លាស់ទីម្រាមដៃផ្សេងទៀតរាងរង្វង់ក្នុងទិសដៅទៅខាងស្តាំ។ **បង្វិលបញ្ច្រាសទ្រនិចនាឡិកា**——ដាក់ម្រាមដៃ ឬមេដៃនៅកន្លែងដាក់ម្រាមដៃអូស ផ្លាស់ទីម្រាមដៃផ្សេងទៀតរាងរង្វង់ក្នុងទិសដៅទៅខាងឆ្វេង។ អ្នកក៏អាចបង្វិល content សកម្មដោយការអូសម្រាមដៃទាំងសងខាងនៅក្នុងចលនារាងជារង្វង់។
អូស 	**ប្តូរ** —ផ្លាស់ទីផ្ដោតលើវត្ថុដែលបានជ្រើសនៅពេលដែលវត្ថុទាំងមូលមិនអាចមើលឃើញ។ ផ្លាស់ទីម្រាមដៃពីរនៅក្នុងទិសចង់បានដើម្បីប្តូរវត្ថុដែលបានជ្រើស។
	**ការអូសផ្ដេក**—អូសឡើង ឬចុះក្រោមនៅលើវិនដូសកម្ម។ ផ្លាស់ទីម្រាមដៃឡើងលើ ឬចុះក្រោមដើម្បីចាប់ផ្តើមអូសបញ្ឈរ។
	• **ការអូសផ្ដេក**—អូសទៅស្តាំ ឬទៅឆ្វេងនៅលើវិនដូសកម្ម។ ផ្លាស់ទីម្រាមម្ខាងទៅស្តាំ ឬទៅឆ្វេងដើម្បីចាប់ផ្តើមអូសផ្តេក។

ការប្រើប្លឺធូស

អ្នកអាចភ្ជាប់ឧបករណ៍ប្លឺធូស (ភ្ជាប់) ដូចជាម៉ៅស៍ ក្តារចុច កាស ឡូស្ពិត ឡូទេស្សព៍ ។ល។ សម្រាប់ព័ត៌មានលម្អិតស្តីពីការភ្ជាប់ឧបករណ៍ប្លឺធូសជាមួយកុំព្យូទ័ររបស់អ្នក សូមមើលឯកសារឧបករណ៍នោះ។

ចំណាំ: ត្រូវប្រាកដថា អ្នកបានដំឡើងកម្មវិធីបញ្ជាប្លឺធូសនៅលើកុំព្យូទ័ររបស់អ្នក។

ការភ្ជាប់ឧបករណ៍ប្លឺធូសជាមួយកុំព្យូទ័រ ឬថេប្លេតរបស់អ្នក

Windows 10

1. បើកប្លឺធូសនៅលើកុំព្យូទ័រ ឬថេប្លេតរបស់អ្នក និងឧបករណ៍ដែលអ្នកកំពុងភ្ជាប់។ នៅលើកុំព្យូទ័រឃ្លួរដៃរបស់ Dell សូមបើកឥតខ្សែដើម្បីបើកប្លឺធូស។

   ចំណាំ: សម្រាប់ព័ត៌មានដើម្បីបើកប្លឺធូសនៅលើឧបករណ៍របស់អ្នកសូមមើលឯកសារដែលភ្ជាប់មកជាមួយឧបករណ៍របស់អ្នក។

2. អូសចូលពីគែមស្តាំនៃអេក្រង់ដើម្បីបើក **Action Center**។
3. ចុច និងសង្កត់ **Bluetooth** រួចប៉ះលើ **Go to settings (ទួលទៅកាន់ការកំណត់)**។
4. ពីបញ្ជីឧបករណ៍ សូមប៉ះឧបករណ៍ដែលអ្នកចង់ភ្ជាប់ជាមួយ និងប៉ះ។

   ចំណាំ: ប្រសិនបើឧបករណ៍របស់អ្នកមិនមានក្នុងបញ្ជី នោះត្រូវប្រាកដថាឧបករណ៍របស់អ្នករកឃើញបាន។

5. ធ្វើតាមការណែនាំដែលបង្ហាញនៅលើអេក្រង់ដើម្បីបញ្ចប់ដំណើរការភ្ជាប់ ។

   ចំណាំ: លេខកូដសម្ងាត់អាចត្រូវបានបង្ហាញនៅលើកុំព្យូទ័រ ឬថេប្លេត និងឧបករណ៍របស់អ្នក។ សារមួយបញ្ជាក់ពីការភ្ជាប់ឧបករណ៍នេះលេចឡើងនៅពេលភ្ជាប់ត្រូវបានបញ្ចប់។

Windows 8.1

1. បើកប្លឺធូសនៅលើកុំព្យូទ័រ ឬថេប្លេតរបស់អ្នក និងឧបករណ៍ដែលអ្នកកំពុងភ្ជាប់។

   នៅលើកុំព្យូទ័រឃ្លួរដៃរបស់ Dell សូមបើកឥតខ្សែដើម្បីបើកប្លឺធូស។

   ចំណាំ: សម្រាប់ព័ត៌មានដើម្បីបើកប្លឺធូសនៅលើឧបករណ៍របស់អ្នកសូមមើលឯកសារដែលភ្ជាប់មកជាមួយឧបករណ៍របស់អ្នក។

2. ចុចម៉ៅស៍ស្តាំលើរូបតំណាងប្លឺធូសនៅក្នុងផ្នែកជ្រុងដំណឹងរបាឧបករណ៍របស់អ្នកហើយចុច ឬប៉ះ **Add a Device**។

   ចំណាំ: ប្រសិនបើអ្នកមិនអាចកំណត់ទីតាំងរូបតំណាងប្លឺធូសបានទេ សូមចុច ឬប៉ះព្រួញក្បែរផ្នែកជ្រុងដំណឹង។

3. នៅក្នុងឡាំង **Add a Device** សូមជ្រើសរើសឧបករណ៍ហើយចុច ឬប៉ះ **Next (បន្ទាប់)**។

   ចំណាំ: ប្រសិនបើឧបករណ៍របស់អ្នកមិនមានក្នុងបញ្ជី នោះត្រូវប្រាកដថាឧបករណ៍របស់អ្នករកឃើញបាន។

4. ធ្វើតាមការណែនាំដែលបង្ហាញនៅលើអេក្រង់ដើម្បីបញ្ចប់ដំណើរការភ្ជាប់ ។

   ចំណាំ: លេខកូដសម្ងាត់អាចត្រូវបានបង្ហាញនៅលើកុំព្យូទ័រ ឬថេប្លេត និងឧបករណ៍របស់អ្នក។

   សារបញ្ជាក់ពីការភ្ជាប់នៃឧបករណ៍នេះនឹងបង្ហាញឡើង ដោយបង្ហាញថា ការភ្ជាប់ត្រូវបានបញ្ចប់។

Windows 7

1. បើកប្លឺធូសនៅលើកុំព្យូទ័រ ឬថេប្លេតរបស់អ្នក និងឧបករណ៍ដែលអ្នកកំពុងភ្ជាប់។ នៅលើកុំព្យូទ័រឃ្លួរដៃរបស់ Dell សូមបើកឥតខ្សែដើម្បីបើកប្លឺធូស។

   ចំណាំ: សម្រាប់ព័ត៌មានដើម្បីបើកប្លឺធូសនៅលើឧបករណ៍របស់អ្នកសូមមើលឯកសារដែលភ្ជាប់មកជាមួយឧបករណ៍របស់អ្នក។

2. ចុច **Start (ចាប់ផ្តើម)** #menucascade-separator **Control Panel (ផ្ទាំងគ្រប់គ្រង)**។
3. នៅក្នុងប្រអប់ស្វែងរក **Control Panel**, វាយបញ្ចូល **Bluetooth**, រួចចុច **កំណត់ការផ្លាស់ប្តូរប្លឺធូស**។
4. ដើម្បីធ្វើឲ្យកុំព្យូទ័ររបស់អ្នករកឃើញឧបករណ៍ប្លឺធូសដែលបានបើក សូមគូសធីករើប្រអប់ **Allow Bluetooth devices to find this computer (អនុញ្ញាតឲ្យឧបករណ៍ប្លឺធូសស្វែងរកកុំព្យូទ័រនេះ។)**

ការប្រើវិបខេម

ប្រសិនបើកុំព្យូទ័រ ឬអេក្រង់របស់អ្នកមានវិបខេមដែលមានប៊ូតុងពាក់មកជាមួយ នោះគ្រាយវីត្រូវបានដំឡើង និងតំណាងឧទានម៉ូនូនៅលាងចក្រ។ វិបខេមត្រូវបានធ្វើសកម្មភាពដោយស្វ័យប្រវត្តិនៅពេលអ្នក ចាប់ផ្តើមការជជែកកំសាន្តជាវីដេអូ ឬកម្មវិធីចាប់យកវីដេអូ។

អ្នកក៏អាចប្រើ Dell Webcam Central (Window 7 តែប៉ុណ្ណោះ) ដើម្បីចាប់យករូបភាពគ្មានចលនា និងវីដេអូដោយប្រើវិបខេមផងដែរ។

ចាប់យករូបភាពគ្មានចលនា

1. បើក **Dell Webcam Central** ។
2. ចុច ឬប៉ះផ្ទាំង **Snap Photos (ថតរូប)** ។
3. ចុចឬ ប៉ះរូបតំណាងកាមេរ៉ាដើម្បីចាប់យករូបភាពគ្មានចលនា។

ចំណាំ: ដើម្បីកំណត់រចនាសម្ព័ន្ធជម្រើសរូបថតជាចំបាំរូបភាព ការកំណត់រយៈពេលដោយខ្លួនឯង ការថតដោយចេញពន្លឺ ទ្រង់ទ្រាយរូបភាព ជាដើម សូមចុច ឬប៉ះព្រួញធ្លាក់ចុះនៅ ជាប់នឹងរូបតំណាងកាមេរ៉ា។

ការថតវីដេអូ

1. បើក **Dell Webcam Central** ។
2. ចុច ឬប៉ះផ្ទាំង **ថតវីដេអូ** ។
3. ចុច ឬប៉ះរូបតំណាងដើម្បីចាប់ផ្តើមថតវីដេអូ។
4. នៅពេលអ្នកបានបញ្ចប់ការថតវីដេអូ សូមចុច ឬប៉ះរូបតំណាងថតម្តងទៀតដើម្បីបញ្ឈប់ការថត។

ចំណាំ: ដើម្បីកំណត់រចនាសម្ព័ន្ធជម្រើសរូបថតជាចំបាំវីដេអូ កំណត់ រយៈពេលដោយខ្លួនឯង, ការកាត់បន្ថយរយៈពេលវេលា ការថត វីដេអូគុណភាព ជាដើម ចុច ឬប៉ះព្រួញធ្លាក់ចុះនៅជាប់ នឹងរូបតំណាងថត។

ការជ្រើសរើសកាមេរ៉ា និងមីក្រូហ្វូន

ប្រសិនបើកុំព្យូទ័ររបស់អ្នកមានកាមេរ៉ា ឬមីក្រូហ្វូនច្រើន (បញ្ចូលគ្នា ឬនៅខាងក្រៅ) អ្នកអាចជ្រើសរើសវិបខេម និងមីក្រូហ្វូនដែលអ្នកចង់ប្រើជាមួយ Dell Webcam Central ។

1. បើក **Dell Webcam Central** ។
2. ចុច ឬប៉ះព្រួញទម្លាក់ចុះនៅជាប់រូបតំណាងកាមេរ៉ានៅជ្រុងខាងឆ្វេងខាងក្រោមនៃវិនដូ។
3. ចុច ឬប៉ះកាមេរ៉ាដែលអ្នកចង់ប្រើ។
4. ចុច ឬប៉ះផ្ទាំង **ថតវីដេអូ** ។
5. ចុច ឬប៉ះព្រួញទម្លាក់ចុះនៅក្បែររូបតំណាងមីក្រូហ្វូននៅជី ក្រោមផ្ទៃមើលជាមុន។
6. ចុច ឬប៉ះមីក្រូហ្វូនដែលអ្នកចង់ប្រើ។

4

រន្ធ និងឧបករណ៍តភ្ជាប់

អូឌីយ៉ូ

ឧបករណ៍តភ្ជាប់អូឌីយ៉ូអនុញ្ញាតឱ្យអ្នកតភ្ជាប់ឧបករណ៍បំពងសំឡេង កាស មីក្រូហ្វូន ប្រព័ន្ធសំឡេង អំភ្លី ឬតភ្ជាប់អូឌីយ៉ូទូទស្សន៍។

ចំណាំ: កុំព្យូទ័ររបស់អ្នកមិនដំណើរការគ្រប់រន្ធអូឌីយ៉ូទាំងអស់ឡើយ។ សម្រាប់ព័ត៌មានបន្ថែមអំពីរន្ធដែលមាននៅលើកំព្យូទ័រ ឬផេបួតរបស់អ្នក សូមមើល *Quick Start Guide (ការណែនាំចាប់ផ្តើមរហ័ស)* ដែលបានភ្ជាប់មកជាមួយកុំព្យូទ័ររបស់អ្នក ឬមើល *Setup and Specifications (ការដំឡើង និងលក្ខណៈបច្ចេកទេស)* តាមរយៈ www.dell.com/support ។

ប្រភេទនៃរន្ធអូឌីយ៉ូ

តារាង 6. ប្រភេទនៃរន្ធអូឌីយ៉ូ

	រន្ធកាស—តភ្ជាប់កាស ឧបករណ៍បំពងសំឡេងដែលមានថាមពល ឬប្រព័ន្ធសំឡេង។
	រន្ធមីក្រូហ្វូន—តភ្ជាប់មីក្រូហ្វូនខាងក្រៅសម្រាប់សំឡេង ឬការបញ្ចូលសំឡេង។
	**រន្ធបណ្តាញចូល**—តភ្ជាប់ឧបករណ៍ថតសំឡេង/ចាក់ចម្រៀងដូចជាឧបករណ៍ចាក់ការ៉ែសត ឧបករណ៍ចាក់ស៊ីឌី ឬ VCR។
	**រន្ធបណ្តាញចេញ**—តភ្ជាប់កាស ឬឧបករណ៍បំពងសំឡេង ដែលមានអំភ្លីរួមបញ្ចូល។
	**រន្ធជុំវិញក្រៅខាងក្រោយ**—ភ្ជាប់ឧបករណ៍បំពងសំឡេងដែលមានឥលហុតាន់ែល។
	ជុំវិញក្រៅកណ្តាល/LFE —ភ្ជាប់ធុងបាស់មួយ។ **ចំណាំ:** នាន់ែលអូឌីយ៉ូ Low Frequency Effects (LFE, ប្រសិទ្ធភាពប្រេកង់ទាប) ដែលមាននៅក្នុងប្រភេទអូឌីយ៉ូសំលេងកណ្តាលឌីជីថល នាំយកព័ត៌មានប្រេកង់ប៉ុណ្ណោះ (80 Hz និងទាបជាងនេះ)។ នាន់ែល LFE បញ្ជាធុងបាស់ដើម្បីផ្តល់កម្រាសខ្លាំងទាប។ ប្រព័ន្ធដែលមិនប្រើធុងបាស់ អាចផ្តល់ព័ត៌មាន LFE ដល់ឧបករណ៍សំឡេងចម្បងនៅក្នុងការរៀបចំសំលេងកណ្តាល។
	**រន្ធកណ្តាលចំហៀង**—ភ្ជាប់ឧបករណ៍បំពងសំឡេងខាងឆ្វេង/ស្តាំ។

តារាង 6. ប្រភេទនៃវន្ឌអូឌីយ៉ូ (បានបន្ត)

	**វន្ឌ RCA S/PDIF**—បញ្ជូនអូឌីយ៉ូឌីជីថលដោយមិនបាច់មានការប៉ះប៉ូវអូឌីយ៉ូអណាឡុក។
	**វន្ឌ S/PDIF អុបទិក**—បញ្ជូនអូឌីយ៉ូឌីជីថលដោយប្រើសញ្ញាអុបទិក ដោយមិនបាច់មានការប៉ះប៉ូវអូឌីយ៉ូអណាឡុក។

USB

Universal Serial Bus (USB) អនុញ្ញាតឲ្យអ្នកភ្ជាប់គ្រឿងកុំព្យូទ័រទៅកុំព្យូទ័រ ឬថេប្លេតបាន។ គ្រឿងកុំព្យូទ័រទាំងនេះរួមមានកូនកណ្តុរ ក្តារចុច ម៉ាស៊ីនព្រីន ក្រាហ្វខាងក្រៅ កាមេរ៉ា ទូរស័ព្ទ។ល។

វន្ឌ USB អាចត្រូវបានប្រើដើម្បីផ្ទេរទិន្នន័យរវាងកុំព្យូទ័រ និងឧបករណ៍របស់អ្នក និងដើម្បីសាកឧបករណ៍ដែលជំរើការជាមួយវាបាន។ សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារសម្រាប់ឧបករណ៍របស់អ្នក។

កុំព្យូទ័រមួយចំនួនក៏មានវន្ឌ USB ដែលរួមបញ្ចូលមុខងារ PowerShare ដែលអនុញ្ញាតឲ្យអ្នកសាកឧបករណ៍ USB របស់អ្នកបានសូម្បីតែនៅពេលកុំព្យូទ័របិទក៏ដោយ។

USB ក៏ដំណើរការជាមួយកម្មវិធី Plug-and-play និង ប្តូរភ្លាមៗផងដែរ

- **Plug-and-Play** —អនុញ្ញាតឲ្យកុំព្យូទ័ររបស់អ្នកស្គាល់ និងកំណត់ឧបករណ៍ដោយស្វ័យប្រវត្តិ។
- **ប្តូរភ្លាមៗ**—អនុញ្ញាតឲ្យអ្នកដក និងភ្ជាប់ឧបករណ៍ USB ដោយមិនចាំបាច់ចាប់ផ្តើមកុំព្យូទ័រឡើងវិញទេ។

វន្ឌ USB

តារាង 7. ប្រភេទនៃវន្ឌ USB

USB ស្តង់ដារ	វន្ឌ USB ស្តង់ដារគាគម្រើនមាននៅលើកុំព្យូទ័រឈ្មួរវែង និងកុំព្យូទ័រលើតុ។ ឧបករណ៍ USB ភាគម្រើនភ្ជាប់ទៅកុំព្យូទ័រដោយប្រើវន្ឌនេះ។
Mini-USB	វន្ឌ Mini-USB ប្រើនៅក្នុងឧបករណ៍អេឡិចត្រូនិចតូចៗដូចជាកាមេរ៉ា ក្រាហ្វក្សាទុកខាងក្រៅ ថេប្លេតជាដើម។
Micro-USB	វន្ឌ micro-USB មានទំហំតូចជាងវន្ឌ mini-USB ហើយគេប្រើប្រាស់នៅក្នុងទូរស័ព្ទ ថេប្លេត កាសតតម្លៃ និងឧបករណ៍អេឡិចត្រូនិចតូចៗផ្សេងទៀត។
USB មានថាមពល	វន្ឌ USB មានថាមពលប្រើឧបករណ៍ភ្ជាប់ស្មុគស្មាញជាង USB ស្តង់ដារ។ វាមានក្បាលភ្ជាប់ពីរនៅក្នុងម៉ែត្រតែមួយ មួយសម្រាប់ដោត USB ស្តង់ដារ និងមួយទៀតសម្រាប់ថាមពលដែលអាចឱ្យឧបករណ៍ថាមពលខ្ពស់ភ្ជាប់បានដោយមិនចាំបាច់ប្រើថាមពលអគ្គិសនី។ វាត្រូវបានប្រើនៅក្នុងឧបករណ៍លក់រាយដូចជាឧបករណ៍អានបារកូដ និងម៉ាស៊ីនព្រីន។

ស្តង់ដារ USB

តារាង 8. ស្តង់ដារ USB

USB 3.1 ជំនាន់ទី 2	វាក៏ត្រូវបានស្គាល់ម្យ៉ាងទៀតថាជា SuperSpeed USB+ ផងដែរ។ វន្ឌនេះគាំទ្រគ្រឿងកុំព្យូទ័រដូចជាឧបករណ៍ផ្ទុក ម៉ាស៊ីនឆោះពុម្ព និងផ្សេងៗទៀត។ ផ្តល់ល្បឿនផ្ទេរទិន្នន័យរហូតដល់ 10 Gbps។ វាអាចរកបានជាមួយការភ្ជាប់ USB ប្រភេទ C និងមានសមត្ថភាពរបស់ជំនាន់ទី 1 បន្ថែមលើ DisplayPort ទៅលើសមត្ថភាពវីដេអូ USB។
USB 3.1 ជំនាន់ទី 1	វាក៏ត្រូវបានស្គាល់ម្យ៉ាងទៀតថាជា SuperSpeed USB ផងដែរ។ វន្ឌនេះគាំទ្រគ្រឿងកុំព្យូទ័រដូចជាឧបករណ៍ផ្ទុក ម៉ាស៊ីនឆោះពុម្ព និងផ្សេងៗទៀត។ ផ្តល់ល្បឿនផ្ទេរទិន្នន័យរហូតដល់ 5 Gbps។ ប្រព័ន្ធដែលមានវន្ឌ Legacy USB 3.0 ឥឡូវនេះគឺជាវន្ឌ USB 3.1 ជំនាន់ទី 1។
USB 2.0	នេះត្រូវបានស្គាល់ថាជា Hi-Speed USB។ វាផ្តល់កម្រិតបញ្ជូនបន្ថែមសម្រាប់កម្មវិធីពហុមេឌៀ និងការផ្ទុក។ USB 2.0 គាំទ្រល្បឿនបញ្ជូនទិន្នន័យរហូតដល់ 480 Mbps។
USB 1.x	ស្តង់ដារ Legacy USB គាំទ្រល្បឿនផ្ទេរទិន្នន័យរហូតដល់ 11 Mbps។
USB PowerShare	លក្ខណៈពិសេស USB PowerShare អនុញ្ញាតឲ្យអ្នកសាកថ្មឧបករណ៍ USB នៅពេលដែលកុំព្យូទ័រត្រូវបានបិទ ឬស្ថិតនៅក្នុងសភាពដេក។ រូបតំណាង រូបតំណាងបង្ហាញថាវន្ឌ USB គាំទ្រលក្ខណៈពិសេស PowerShare។ **ចំណាំ:** ឧបករណ៍ USB ជាក់លាក់មួយចំនួនអាចមិនសាកថ្ម នៅពេលដែលកុំព្យូទ័រត្រូវបានបិទ ឬស្ថិតក្នុងសភាពដេក។ ក្នុងករណីនោះ សូមបើកកុំព្យូទ័រដើម្បីសាកថ្មឧបករណ៍។ **ចំណាំ:** បើសិនជាអ្នកបិទកុំព្យូទ័ររបស់អ្នក ខណៈពេលកំពុងសាកថ្មឧបករណ៍ USB នោះឧបករណ៍អាចឈប់សាកថ្ម។ ដើម្បីបន្តសាកថ្ម សូមផ្តាច់ឧបករណ៍ និងភ្ជាប់វាម្តងទៀត។ **ចំណាំ:** នៅលើកុំព្យូទ័រឈ្មួរវែង លក្ខណៈពិសេស PowerShare ឈប់សាកថ្មឧបករណ៍ នៅពេលដែលថ្មកុំព្យូទ័រឈ្មួរវែងធ្លុះដល់ 10%។ អ្នកអាចកំណត់រចនាសម្ព័ន្ធដែលកំណត់នេះដោយប្រើប្រាស់កម្មវិធីតំឡើង BIOS។

តារាង 8. ស្តង់ដារ USB (បានបន្ត)

USB-C	អាស្រ័យលើឧបករណ៍របស់អ្នក វគ្គនេះអាចគាំទ្រ USB 3.1, ការបង្ហាញតាម USB-C, និងឧបករណ៍ Thunderbolt 3។ ចំពោះព័ត៌មានបន្ថែម សូមមើលឯកសារដែលភ្ជាប់មកជាមួយឧបករណ៍របស់អ្នក។
វគ្គ Thunderbolt 3 (USB C)	អ្នកអាចតភ្ជាប់ USB 3.1 ជំនាន់ទី 2, USB 3.1 ជំនាន់ទី 1, DisplayPort, និងឧបករណ៍ Thunderbolt ជាមួយវគ្គនេះ។ វាអនុញ្ញាតឱ្យអ្នកតភ្ជាប់ទៅអក្រង់ខាងក្រៅដោយប្រើប្រាស់ឧបករណ៍ដោត។ ផ្តល់អត្រាផ្ទេរទិន្នន័យរហូតដល់ 40 Gbps។
វគ្គបំបាត់កំហុស	វគ្គបំបាត់កំហុស អនុញ្ញាតឱ្យអ្នកប្រើដំណើរការវគ្គ USB 3.0 នៅក្នុងម៉ូដ USB 2.0 ជាបណ្តោះអាសន្នក្នុងគោលបំណងដោះស្រាយបញ្ហា និងនៅពេលដែលប្រព័ន្ធប្រតិបត្តិការត្រូវបានដំឡើងឡើងវិញដោយប្រើប្រាស់ក្រាយអុបទិក ឬក្រាយហ្គាស។

eSATA

eSATA អនុញ្ញាតឱ្យអ្នកភ្ជាប់ឧបករណ៍ផ្ទុកខាងក្រៅដូចជាក្រាយថាសរឹង និងក្រាយអុបទិកទៅកុំព្យូទ័ររបស់អ្នក។ ផ្តល់នូវកម្រិតបញ្ជូនដូចគ្នានឹងវគ្គ SATA ខាងក្នុងដែរ។

កុំព្យូទ័ររបស់អ្នកអាចមានវគ្គ eSATA ដាច់ដោយឡែក ឬវគ្គ eSATA / USB ជាមួយគ្នា។

Visual Graphics Array (អារេក្រាហ្វិចមើលឃើញ)

Visual Graphics Array (VGA) អនុញ្ញាតឱ្យអ្នកភ្ជាប់ទៅ ម៉ូនីទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ ។ល។

អ្នកអាចភ្ជាប់ទៅវគ្គ HDMI ឬ DVI ដោយប្រើប្រាស់ VGA ទៅ HDMI ឬ VGA ទៅ DVI ។

Digital Visual Interface (ចំណុចប្រទាក់ឌីជីថលរូបភាព)

Digital Visual Interface (DVI) អាចឱ្យអ្នកភ្ជាប់កុំព្យូទ័រទៅនឹងអក្រង់ដូចជាផ្ទាំងម៉ូនីទ័រអាបស្មើ និងឧបករណ៍បញ្ចាំងស្លាយ ។ល។

ឧបករណ៍ភ្ជាប់ DVI មានចំប្រភេទគឺ៖

- **DVI-D (DVI-Digital, DVI-ឌីជីថល)**—DVI-D បញ្ជូនសញ្ញាវីដេអូឌីជីថលរវាងកាតវីដេអូ និងអក្រង់ឌីជីថល។ ធ្វើឱ្យការបញ្ចេញវីឌីអូមានគុណភាពខ្ពស់ និងលឿន។
- **DVI-A (DVI-Analog, DVI-អាណាឡុក)**—DVI-A បញ្ជូនសញ្ញាវីដេអូអាណាឡុកទៅកាន់អក្រង់អាណាឡុកដូចជាម៉ូនីទ័រ CRT ឬ ម៉ូនីទ័រ LCD អាណាឡុក ។
- **DVI- I (DVI-Integrated, DVI-បញ្ចូលគ្នា)**—DVI-I ជាឧបករណ៍ភ្ជាប់បញ្ចូលគ្នាដែលអាចបញ្ជូនបានទាំងសញ្ញាឌីជីថល ឬអាណាឡុក។ វគ្គនេះមានភាពងាយស្រួលដែលអាចប្រើបានទាំងឧបករណ៍ភ្ជាប់ឌីជីថល និងអាណាឡុក។

DisplayPort

DisplayPort ផ្តល់នូវការភ្ជាប់ឌីជីថលរវាងកុំព្យូទ័រ និងឧបករណ៍បង្ហាញរបស់អ្នកដូចជាម៉ូនីទ័រ ឧបករណ៍បញ្ចាំងស្លាយជាដើម។ វាគាំទ្រទាំងស៊ីញ៉ាល់វីដេអូ និងអូឌីយ៉ូ។ DisplayPort ត្រូវបានឧទាហរណ៍ជាពិសេសសម្រាប់ប្រើជាមួយអក្រង់កុំព្យូទ័រ។

វគ្គអក្រង់ខ្នាតតូច

Mini DisplayPort គឺជាកំណែតូចជាង DisplayPort ។

ចំណាំ: DisplayPort និង Mini DisplayPort គឺត្រូវជាមួយគ្នាប៉ុន្តែវគ្គ និងឧបករណ៍ភ្ជាប់មានចំហំខុសៗគ្នា។ ប្រសិនបើចំហំវគ្គខុសគ្នា ត្រូវប្រើឧបករណ៍បម្លែង។

អត្ថប្រយោជន៍នៃ DisplayPort

- គាំទ្រដល់គុណភាពបង្ហាញ និងអត្រាធ្វើឱ្យថ្មីខ្ពស់
- គាំទ្រការបញ្ជូន 3D
- គាំទ្រឧបករណ៍បង្ហាញច្រើនក្នុងពេលដំណាលគ្នា
- គាំទ្រការការពារខ្លឹមសារឌីជីថលកម្រិតបញ្ជូនខ្ពស់ (HDCP)
- គាំទ្ររអាច់ទ័រដោតហើយប្រើបានដែលអនុញ្ញាតឱ្យអ្នកភ្ជាប់អក្រង់ដោយប្រើស្តង់ដារភ្ជាប់ចាស់ៗដូចជា DVI, HDMI និង VGA ។
- ខ្សែ DisplayPort អាចពង្រីករហូតដល់ 15 ម៉ែត្រ (49,21 ហ្វីត) ដោយមិនត្រូវការឧបករណ៍បង្កើនស៊ីញ៉ាល់ឡើយ។

HDMI

HDMI ផ្តល់នូវការភ្ជាប់ឌីជីថលរវាងកុំព្យូទ័រ ឧបករណ៍បង្ហាញ និងឧបករណ៍ពហុមេឌៀផ្សេងៗទៀតរបស់អ្នក។ វាដំណើរការទាំងសញ្ញាវីដេអូ និងអូឌីយ៉ូ។

រន្ធ HDMI ជាទូទៅមាននៅលើកុំព្យូទ័រ ទូរទស្សន៍ ម៉ាស៊ីនចាក់ឌីជីថល ឌីវីឌី និង Blu-ray ហ្គេមកម្សាន្តជាដើម។

គុណសម្បត្តិរបស់ HDMI

- គាំទ្រគុណភាពបង្ហាញខ្ពស់ និងកម្រិតវិប្រូសខ្ពស់
- គាំទ្រចំពោះការបញ្ជូន 3D
- គាំទ្រជាមួយ HDCP
- ជាទូទៅមាននៅក្នុងកុំព្យូទ័រភាគច្រើន និងឧបករណ៍ពហុមេឌៀរបស់អ្នកប្រើប្រាស់
- អាចប្រើដើម្បីដំឡើងវគ្គអូឌីយ៉ូ វីដេអូ ឬការភ្ជាប់អូឌីយ៉ូនិ ងវីដេអូវគ្គបុ៉ណ្ណោះ
- ត្រូវគ្នាជាមួយនឹងអេក្រង់ថេរឬតង្កូចជា LCDs អេក្រង់ផ្ទាស្មា និងម៉ាស៊ីនបញ្ចាំងស្លាយ

Mini HDMI

Mini HDMI ផ្តល់នូវការភ្ជាប់ឌីជីថលរវាងកុំព្យូទ័រ និងឧបករណ៍ចល័តរបស់អ្នកដូចជាស្មាតហ្វូន កុំព្យូទ័រយួរដៃជាដើម។

Micro HDMI

Micro HDMI ផ្តល់នូវការភ្ជាប់ឌីជីថលរវាងកុំព្យូទ័រ និងឧបករណ៍ចល័តរបស់អ្នកដូចជាស្មាតហ្វូន កុំព្យូទ័រយួរដៃជាដើម។ ឧបករណ៍ភ្ជាប់នេះប្រហាក់ប្រហែលនឹងឧបករណ៍ភ្ជាប់ micro-USB ដែលមាននៅលើស្មាតហ្វូនភាគច្រើន។

SPDIF

S/PDIF គឺជាស្តង់ដារសម្រាប់ផ្ទេរអូឌីយ៉ូជាទ្រង់ទ្រាយ ឌីជីថល។ អ្នកអាចប្រើ S/PDIF ទៅឧបករណ៍អូឌីយ៉ូដូចជាកាត សំឡេង ឧបករណ៍បំពងសំឡេង ប្រព័ន្ធសំឡេងនៅផ្ទះ ទូរទស្សន៍ជាដើម។ វាផ្តល់នូវការគាំទ្រអូឌីយ៉ូ 5.1 ។

មានពីរប្រភេទនៃការភ្ជាប់ S/PDIF៖

- **អុបទិក** - ប្រើអុបទិកហ្វាយប័រជាមួយឧបករណ៍ភ្ជាប់ TOSLINK
- **អ័ក្សរួម** - ប្រើខ្សែអ័ក្សរួមជាមួយឧបករណ៍ភ្ជាប់ RCA

Absolute

Absolute ផ្តល់ជូនអ្នកនូវដំណោះស្រាយគ្រប់គ្រងហានិភ័យចុងក្រោយ និងសន្តិសុខគ្រប់ចំណុច សម្រាប់កុំព្យូទ័រ ថេប្លេត និងស្មាតហ្វូន។ បច្ចេកវិទ្យាដែលមានភាពរឹងមាំអនុញ្ញាតឱ្យអ្នកវាយតម្លៃហានិភ័យជាប់លាប់ ធានានូវអាយុកាលនៃឧបករណ៍ដ៏មានតម្លៃ និងធ្វើឱ្យតបទៅនឹងការបង្ការនូវឧប្បត្តិហេតុសុវត្ថិភាពសន្តិសុខផងដែរ។

ចំណាំ: បច្ចេកវិទ្យាដែលមានភាពរឹងមាំអាចមិនដំណើរការនៅលើកុំព្យូទ័រទាំងអស់នោះទេ។

ស្វែងរកជំនួយអំពី Absolute

Dell ផ្តល់ជំនួយលើបច្ចេកវិទ្យាដែលមានភាពរឹងមាំតាមរយៈសូហ្វវែរ Absolute ។ អ្នកអាចទាក់ទងសូហ្វវែរ Absolute សម្រាប់ជំនួយអំពីការដំឡើង ការកំណត់រចនាសម្ព័ន្ធ ការប្រើប្រាស់ និងការដោះស្រាយបញ្ហា។

ដើម្បីទាក់ទង Absolute Software សូមមើលគេហទំព័ររបស់ Absolute Software តាមរយៈ: www.absolute.com ឬអ៊ីមែលទៅ techsupport@absolute.com ។

Dell SupportAssist

SupportAssist ផ្តល់ព័ត៌មានអំពីផលិតផល គំរូ ការជូនដំណឹងអំពីហានិភ័យ ស្ថានសេវាកម្ម លេខកូដសេវាកម្មរហ័ស និងព័ត៌មានលម្អិតពីការធានា។ លក្ខណៈពិសេសមួយចំនួនរួមមាន៖

- **ការជូនដំណឹង** – ផ្តល់សារអំពីសុខភាពទូទៅនៃប្រព័ន្ធ និងផ្តល់នូវជម្រើសជួយខ្លួនឯងដើម្បីដោះស្រាយបញ្ហា។
- ស្ថានភាព**ពិនិត្យ** – ផ្តល់ជូននូវព័ត៌មាននៃការវិនិច្ឆ័យ ឧបករណ៍ និងកម្មវិធីមានប្រយោជន៍ដើម្បីចាប់អក និងដោះស្រាយបញ្ហាប្រព័ន្ធ។
- **ព័ត៌មានប្រព័ន្ធ** – ផ្តល់ព័ត៌មានពេញលេញអំពីសូហ្វវែរប្រព័ន្ធ និងការកំណត់រចនាសម្ព័ន្ធផ្នែករឹង។
- **ការគាំទ្រ** – ផ្តល់ជូននូវព័ត៌មានគាំទ្រផលិតផលដូចជា៖ ជម្រើសទំនាក់ទំនង សៀវភៅណែនាំ ជំនួយ និងម្រើនទៀត។ តំណភ្ជាប់ទាងក្រោម និងធនធានរបស់ Dell មាននៅក្នុង ផ្នែកជំនួយ

ការទាញយក Dell SupportAssist

SupportAssist ត្រូវបានតំឡើងរួចហើយនៅលើកុំព្យូទ័រ Dell និង ថេប្លេតថ្មីទាំងអស់។ ដើម្បីតំឡើង SupportAssist សូមទាញយកកម្មវិធី ហើយដំណើរការកម្មវិធីដំឡើង។

ចូលប្រើ SupportAssist

- **Windows 10** - ចុច ឬប៉ះលើរូបតំណាង **Dell Help & Support (ជំនួយ និងការគាំទ្រ Dell)** នៅលើអក្រង់ **ចាប់ផ្តើម**។
- **Windows 8.1** - ចុច ឬប៉ះលើរូបតំណាង **My Dell (Dell របស់ខ្ញុំ)** នៅលើអក្រង់ចាប់ផ្តើម។
- **Windows 7** - ចុច **Start**#menucascade-separator **All Programs (កម្មវិធីទាំងអស់)**#menucascade-separator **Dell** #menucascade-separator**My Dell**#menucascade-separator **My Dell** ។

ពិនិត្យកុំព្យូទ័រ

ចំណាំ: PC checkup (ការត្រួតពិនិត្យកុំព្យូទ័រ) អាចប្រើបានតែលើម៉ូដែលបានជ្រើសរើសប៉ុណ្ណោះ។

ប្រើ PC checkup (ការត្រួតពិនិត្យកុំព្យូទ័រ) ដើម្បីពិនិត្យការប្រើប្រាស់ក្រាយថាសរឹងរបស់អ្នក ដំណើរការវិភាគហាតវែរ និងតាមដានការផ្លាស់ប្តូរដែលបានធ្វើទៅលើកុំព្យូទ័ររបស់អ្នក។

- **Drive Space Manager (កម្មវិធីគ្រប់គ្រងចំហាយ)**—គ្រប់គ្រងគ្រាយថាសរឹងរបស់អ្នកដោយប្រើតំណាងដែលមើលឃើញនៃទំហំដែលបានប្រើតាមប្រភេទឯកសារនីមួយៗ។
- **Performance and Configuration History (ប្រវត្តិការអនុវត្ត និងការកំណត់រចនាសម្ព័ន្ធ)**—តាមដានព្រឹត្តិការណ៍ប្រព័ន្ធ និងការផ្លាស់ប្តូរតាមពេលវេលា។ ឧបករណ៍នេះបង្ហាញពីការស្ទុនហាតវែរ ការធ្វើតេស្ត ការផ្លាស់ប្តូរប្រព័ន្ធ ព្រឹត្តិការណ៍សំខាន់ៗ និងចំណុចស្តារឡើងវិញនៃប្រព័ន្ធ។
  - **Detailed System Information (ព័ត៌មានប្រព័ន្ធលម្អិត)**—បង្ហាញព័ត៌មានលម្អិតអំពីការកំណត់រចនាសម្ព័ន្ធហាតវែរ និងប្រព័ន្ធប្រតិបត្តិការរបស់អ្នក។ ទទួលបានច្បាប់ថតចម្លងកិច្ចសន្យាសេវាកម្មរបស់អ្នក ព័ត៌មានអំពីការធានា និងជម្រើសបន្ថែមការធានា។
  - **Get Help (ទទួលជំនួយ)**—មើលជម្រើសជំនួយបច្ចេកទេសរបស់ Dell, ជំនួយអតិថិជន, ការណែនាំ និងបណ្តុះបណ្តាល, ឧបករណ៍អនឡាញ, សៀវភៅណែនាំស្តីពីសេវាកម្ម ព័ត៌មានធានា, សំណួរចម្លើយ, ។ល។
  - **Backup and Recovery (ការបង្កើតទុក និងការទាញយកមកវិញ)**— ចូលប្រើឧបករណ៍ទាញយកប្រព័ន្ធមកវិញដែលអនុញ្ញាតឱ្យអ្នក៖
    - បង្កើតឯកសារ Dell Factory Image Restore (ស្តារឡើងវិញនូវរូបភាពដែលមានស្រាប់ពីហាងចក្រ Dell) នៅលើកុំព្យូទ័ររបស់អ្នកដើម្បីស្តារកុំព្យូទ័រឡើងវិញនៅពេលក្រោយ។

- បង្កើតមេរៀបម្រុងទុក និងការទាញយកមកវិញ
- **System Performance Improvement Offers(ការផ្តល់ជូនអ្នកលក់លម្អិតប្រព័ន្ធ)**—ផ្តល់ជូន ដំណោះស្រាយហាដវែរ និងសូហ្វវែរដែលជួយធ្វើឱ្យប្រតិបត្តិការប្រព័ន្ធរបស់អ្នកប្រសើរឡើង។

Quickset

Quickset គឺជាឈុតនៃកម្មវិធីសូហ្វវែរ ដែលផ្តល់មុខងារកាន់តែប្រសើរឡើងដល់កុំព្យូទ័រ Dell របស់អ្នក។ វាផ្តល់នូវភាពងាយស្រួលក្នុងការចូលទៅកាន់មុខងារជាច្រើនដែលជាធម្មតាមានជំហានជាច្រើន។ លក្ខណៈពិសេសមួយចំនួនដែលអ្នកអាចចូលប្រើ Dell Quickset រួមមាន៖

- កំណត់រចនាសម្ព័ន្ធគ្រាប់ចុចផ្លូវកាត់ឥតខ្ចោះ។
- បិទ ឬបើកការសាកថ្ម។
- ប្តូរតវិយាបថគ្រាប់ចុច Fn ។

ចំណាំ: Quickset អាចមិនដំណើរការនៅលើកុំព្យូទ័រទាំងអស់ទេ។

ការដំឡើង Quickset

Quickset ត្រូវបានដំឡើងជាមុនលើកុំព្យូទ័រ Dell ថ្មី។ ប្រសិនបើអ្នកត្រូវការដំឡើង Quickset ឡើងវិញសូមទាញយកព័ត៌មានជំនួយរបស់ Dell តាមរយៈ www.dell.com/support ។

ចំណាំ: ប្រសិនបើអ្នកស្តារកុំព្យូទ័ររបស់អ្នកឡើងវិញដោយប្រើ PC Restore ឬកម្មវិធីដែលស្រដៀងគ្នា នោះ Quickset ក៏ត្រូវបានស្តារឡើងវិញផងដែរ។

កម្មវិធី NVIDIA 3D

កម្មវិធីចាក់ NVIDIA 3DTV ដែលបានដំឡើងនៅលើកុំព្យូទ័ររបស់អ្នកអនុញ្ញាតឱ្យអ្នកលេងហ្គេម 3D មើលវីដេអូ Blu-ray 3D និងមើលរូបភាព 3D ។ វាដំណើរការហ្គេមដូចគ្នាជា NVIDIA 3D Vision ដែរ។ សម្រាប់បញ្ជីហ្គេម 3D ដែលអាចលេងបានសូមចូលទៅ www.nvidia.com ។

ចំណាំ: សូមមើលជំនួយផ្នែក NVIDIA សម្រាប់ព័ត៌មានលម្អិតអំពីកម្មវិធីនេះ។

ចំណាំ: កម្មវិធី NVIDIA 3D មិនមាននៅលើកុំព្យូទ័រទាំងអស់ទេ។

លេងហ្គេមជា 3D

1. បើកដំណើរការហ្គេមម៉ូដពេញអេក្រង់។
2. ប្រសិនបើអ្នកឃើញសារមួយបញ្ជាក់ថាម៉ូដបច្ចុប្បន្នមិនត្រូវគ្នាជាមួយអន្ត HDMI v1.4 សូមកំណត់គុណភាពនៅក្នុងហ្គេមទៅជា 1280 x 720 (720p) នៅក្នុងម៉ូដ HD 3D ។

ក្តារចុចផ្លូវកាត់

ខាងក្រោមនេះគឺជាក្តារចុចផ្លូវកាត់មួយចំនួនដែលមានសម្រាប់ការលេងហ្គេម 3D ។

តារាង 9. ក្តារចុចផ្លូវកាត់ សម្រាប់ហ្គេម 3D

គ្រាប់ចុច	បរិយាយ	មុខងារ
<Ctrl><t>	បង្ហាញ/លាក់រូបភាព 3D stereoscopic (ស្ទេរីអូស្កូពិច)	បើក ឬបិទ 3DTV Play ។ **ចំណាំ:** ការលេងហ្គេមអាចកាត់បន្ថយនៅពេលប្រើម៉ូដ 3D HD ទោះបីជា 3DTV Play ត្រូវបានបិទក៏ដោយ។ ដើម្បីបង្កើនការលេងសូមប្រើសរើសម៉ូដ HD ឬ SD នៅពេលដែល 3DTV Play ត្រូវបានបិទ។
<Ctrl><F4>	បង្កើនកម្រិតជម្រៅ 3D	បង្កើនកម្រិតជម្រៅ 3D នៅក្នុងហ្គេមបច្ចុប្បន្ន។
<Ctrl><F3>	បន្ថយកម្រិតជម្រៅ 3D	បន្ថយកម្រិតជម្រៅ 3D នៅក្នុងហ្គេមបច្ចុប្បន្ន។
<Ctrl><F11>		ថតរូប 3D នៃហ្គេមបច្ចុប្បន្នហើយរក្សាទុកឯកសារនៅក្នុងសឺមុីនៅក្នុងសឺមុី **ឯកសារ** ។ ដើម្បីមើលឯកសារ សូមប្រើកម្មវិធីមើលរូបភាព NVIDIA 3D ។
<Ctrl><Alt><Insert>	បង្ហាញ/លាក់សារដែលត្រូវគ្នានៅក្នុងហ្គេម	បង្ហាញការកំណត់ដែលបានណែនាំពី NVIDIA សម្រាប់ហ្គេមបច្ចុប្បន្ន។
<Ctrl><F6>	បង្កើនការរួមបញ្ចូលគ្នា	ផ្លាស់ទីវត្ថុទៅកម្រិត ការរួមបញ្ចូលអតិបរមាដោយដាក់វត្ថុទាំងអស់នៅពីមុខឈុតឆាកកន្លែងរបស់អ្នក និងត្រូវបានប្រើដើម្បីដាក់សញ្ញាឡាស៊ែរផងដែរ។

តារាង 9. ក្តារចុចផ្លូវកាត់ សម្រាប់ឈ្លុច 3D (បានបន្ត)

គ្រាប់ចុច	បរិយាយ	មុខងារ
<Ctrl><F5>	បន្តុយការរួមបញ្ចូលគ្នា	ផ្តាស់ទីវត្ថុឆ្ងាយពីអ្នក ការរួមបញ្ចូលអប្បបរមាដោយដាក់វត្ថុទាំងអស់នៅពីក្រោយឈុតឆាកនៃកន្លែងរបស់អ្នក និងត្រូវបានប្រើដើម្បីដាក់សញ្ញាឡូរ៉ែសិរផងដែរ។

ចំណាំ: សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសារជំនួយកម្មវិធី NVIDIA ។

6

ការស្តារប្រព័ន្ធដំណើរការរបស់អ្នកឡើងវិញ

ជម្រើសស្តារប្រព័ន្ធឡើងវិញ

ប្រយ័ត្ន: ការប្រើ Dell Factory Image Restore (ស្តារឡើងវិញនូវរូបភាពដែលមានស្រាប់ពីរោងចក្រ Dell) ឬនីសប្រព័ន្ធប្រតិបត្តិការនឹងលុបឯកសារទាំងស្រុងនៅលើកុំព្យូទ័ររបស់អ្នកជាអចិន្ត្រៃយ៍។ លើសពេ អ្នកត្រូវបង្កើតទុកទិន្នន័យមុនពេលប្រើនូវជម្រើសទាំងនេះ។

អ្នកអាចស្តារប្រព័ន្ធប្រតិបត្តិការនៅលើកុំព្យូទ័ររបស់អ្នកដោយប្រើជម្រើសណាមួយខាងក្រោម៖

តារាង 10. ជម្រើសស្តារប្រព័ន្ធឡើងវិញ

ជម្រើស	ចរិយាយ
ការបង្កើតទុក និងការសង្គ្រោះឯកសាររបស់ Dell	ប្រើជម្រើសនេះជាដំណោះស្រាយដំបូងដើម្បីទាញយកប្រព័ន្ធប្រតិបត្តិការរបស់អ្នកមកវិញ។
ឌីសដំឡើងប្រព័ន្ធឡើងវិញ	ប្រើជម្រើសនេះនៅពេលប្រព័ន្ធដំណើរការបរាជ័យដែលរារាំងការប្រើប្រាស់ Dell Backup and Recovery (ការបង្កើតទុក និងការសង្គ្រោះឯកសាររបស់ Dell) ឬនៅពេលដំឡើង Windows នៅលើគ្រាយថាសរឹងថ្មី ឬជំនួស។
ស្តារប្រព័ន្ធឡើងវិញ	ប្រើជម្រើសនេះដើម្បីស្តារការកំណត់រចនាសម្ព័ន្ធប្រព័ន្ធប្រតិបត្តិការរបស់អ្នកទៅចំណុចមួយមុនដោយមិនប៉ះពាល់ដល់ឯកសាររបស់អ្នកឡើយ។
ស្តារឡើងវិញនូវរូបភាពដែលមានស្រាប់ពីរោងចក្រDell	ប្រើវាជាជម្រើសចុងក្រោយដើម្បីស្តារប្រព័ន្ធប្រតិបត្តិការរបស់អ្នកឡើងវិញ។ វិធីសាស្ត្រនេះលុបឯកសារ និងកម្មវិធីទាំងអស់ដែលអ្នករក្សាទុក ឬតម្លើងនៅលើកុំព្យូទ័ររបស់អ្នក។

ការបង្កើតទុក និងការសង្គ្រោះឯកសាររបស់ Dell

ការបង្កើតទុក និងការសង្គ្រោះឯកសាររបស់ Dell មានពីរកំណែ៖

- ការបង្កើតទុក និងការសង្គ្រោះឯកសាររបស់ Dell មូលដ្ឋាន
- ការបង្កើតទុក និងការសង្គ្រោះឯកសាររបស់ Dell កម្រិតខ្ពស់

តារាង 11. លក្ខណៈពិសេសនៃការបង្កើតទុក និងការសង្គ្រោះឯកសាររបស់ Dell

លក្ខណៈពិសេស	មូលដ្ឋាន	កម្រិតខ្ពស់
ស្តារប្រព័ន្ធរបស់អ្នកត្រឡប់ទៅស្ថានភាពពីរោងចក្រ	✓	✓
បម្រុងទុកឯកសារដោយដៃ	✓	✓
ស្តារឯកសារពីការបម្រុងទុក	✓	✓
បម្រុងទុកឯកសារជាបន្តបន្ទាប់ ដើម្បីកាត់បន្ថយការបាត់បង់ទិន្នន័យ	✗	✓
បង្កើតការបម្រុងទុកប្រព័ន្ធរពេញលេញ រាប់បញ្ចូលទាំងកម្មវិធី និងការកំណត់	✗	✓

តារាង 11. លក្ខណៈពិសេសនៃការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell (បានបន្ត)

លក្ខណៈពិសេស	មូលដ្ឋាន	កម្រិតខ្ពស់
បញ្ចូលការបម្រុងទុកច្រើនចូលគ្នា និងទុកការបម្រុងទុកចាស់ក្នុងប័ណ្ណសារ	✗	✓
បម្រុងទុក និងស្តារឯកសារផ្អែកលើប្រភេទ	✗	✓

ការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell មូលដ្ឋាន

ការចូលប្រើ Dell Backup and Recovery

Windows 10

1. ចុច **Start**, វាយបញ្ចូល **Backup** នៅក្នុងប្រអប់ស្វែងរក។
2. ចុចរូបតំណាង **Dell Backup and Recovery** ហើយធ្វើតាមការណែនាំនៅលើអេក្រង់។

Windows 8

1. ចូលអ្នប្រើប៊ូតុងមុខងារស្វែងរក
2. ចុច ឬប៉ះ **Apps** ហើយវាយបញ្ចូល **Dell Backup and Recovery** នៅក្នុងប្រអប់ស្វែងរក។
3. ចុច ឬប៉ះ **Dell Backup and Recovery** នៅក្នុងបញ្ជីលទ្ធផលស្វែងរក ហើយអនុវត្តតាមការណែនាំនៅលើអេក្រង់។

ការបង្កើតឌីសដំឡើងប្រព័ន្ធឡើងវិញ

1. បើកដំណើរការ **Dell Backup and Recovery (បម្រុងទុក និងការស្តារឯកសាររបស់ Dell)**។
2. ចុច ឬប៉ះលើចំណងជើង **Factory Recovery Media** ។
3. អនុវត្តតាមការណែនាំនៅលើអេក្រង់។

ការស្តារកុំព្យូទ័ររបស់អ្នកឡើងវិញ

1. បើកដំណើរការ **Dell Backup and Recovery (បម្រុងទុក និងការស្តារឯកសាររបស់ Dell)**។
2. ចុច ឬប៉ះលើ **Recovery** ។
3. ចុច ឬប៉ះលើ **System Recovery (ស្តារប្រព័ន្ធ)**។
4. ចុច ឬប៉ះ **Yes, Continue (យល់ព្រម បន្ត)**។
5. អនុវត្តតាមការណែនាំនៅលើអេក្រង់។

Dell Backup and Recovery premium

ប្រយ័ត្ន: **ទោះបីជាអ្នកត្រូវបានផ្តល់ជូនឥតគិតថ្លៃជាមួយសារធាតុបំពេញកន្លែងដំណើរការស្តារកំណាយ ក៏វាត្រូវបានណែនាំឱ្យអ្នកបម្រុងទុកឯកសារផ្ទាល់ខ្លួនរបស់អ្នកលើគ្រាយ ឬនីសង្ខាច់ណាយច័ព្ទកម្លួយ មុនពេលប្រើជម្រើសស្តារឡើងវិញនេះ។**

ចំណាំ: ប្រសិនបើអ្នកបានបញ្ជាទិញ Dell Backup and Recovery Premium ជាមួយនឹងកុំព្យូទ័ររបស់អ្នកតាមរយៈកម្មវិធី Delivery Digital នោះអ្នកចាំបាច់ត្រូវទាញយក Dell Backup and Recovery Basic ជាមុនសិនដើម្បីទទួលបានជម្រើស Dell Backup and Recovery Premium ។

ការតម្លើងជំនាន់ទៅការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell កម្រិតខ្ពស់

1. ចាប់ផ្តើម **ការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell** ។
2. ចុច ឬប៉ះលើ **Backup (ការបម្រុងទុក)** ហើយជ្រើស **Data Backup (បម្រុងទុកទិន្នន័យ)** ។

3. ចុច ឬប៉ះ **Upgrade to Dell Backup and Recovery Premium (តម្លើងដំឡាន់ទៅជាការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell កម្រិតខ្ពស់)** ។

ការស្តារទិន្នន័យពីការបម្រុងទុកប្រព័ន្ធ

1. បើក **Dell Backup and Recovery (បម្រុងទុក និងការស្តារឯកសាររបស់ Dell)**។
2. ចុច ឬប៉ះ **Backup (ការបម្រុងទុក)** និងជ្រើសរើស **System Backup (ការបម្រុងទុកប្រព័ន្ធ)**។
3. ធ្វើតាមការណែនាំនៅលើអេក្រង់។

ការស្តារឯកសារ ឬថតឯកសារជាក់លាក់ពីការបម្រុងទុកប្រព័ន្ធពេញលេញ

1. បើកដំណើរការ **Dell Backup and Recovery (បម្រុងទុក និងការស្តារឯកសាររបស់ Dell)**។
2. ចុច ឬប៉ះ **Recovery** រួចជ្រើសរើស **Data Recovery (ការស្តារទិន្នន័យ)**។
3. ចុច ឬប៉ះ **Yes, Continue (យល់ព្រម បន្ត)**។
4. អនុវត្តតាមការណែនាំនៅលើអេក្រង់។

ការស្តារឯកសារ ឬថតឯកសារជាក់លាក់ពីការបម្រុងទុកឯកសារ និងថតឯកសារ

1. បើកដំណើរការ **Dell Backup and Recovery (បម្រុងទុក និងការស្តារឯកសាររបស់ Dell)**។
2. ចុច ឬប៉ះលើ **Recovery** រួចជ្រើសរើស **Recover your Data (ការស្តារទិន្នន័យរបស់អ្នកឡើងវិញ)**។
3. ចុច ឬប៉ះលើ **Browse**, ជ្រើសរើសឯកសារ និងថតឯកសាររបស់អ្នក រួចចុច **OK (យល់ព្រម)**។
4. ចុច ឬប៉ះ **Restore Now (ស្តារឥឡូវនេះ)**។
5. អនុវត្តតាមការណែនាំនៅលើអេក្រង់។

ការបង្កើតការបម្រុងទុកប្រព័ន្ធពេញលេញ

1. បើកដំណើរការ **Dell Backup and Recovery (ការបម្រុងទុក និងការសង្គ្រោះឯកសាររបស់ Dell)**។
2. ចុច ឬប៉ះទៅលើពាក្យ **Backup (បម្រុងទុក)** រួចជ្រើសរើស **ការសង្គ្រោះឯកសារប្រព័ន្ធ (System Recovery)**។
3. ចុច ឬប៉ះលើពាក្យ **បម្រុងទុកឥឡូវនេះ (Backup Now)**។
4. អនុវត្តតាមការណែនាំនៅលើអេក្រង់

ការស្តារឡើងវិញនូវរូបភាពដែលមានស្រាប់ពីរោងចក្រ Dell

ប្រយ័ត្ន: ការប្រើជម្រើស Dell Factory Image Restore លប់កម្មវិធី ក្រាយវើរណាដែលបានតំឡើងជាផលចិត្តឡើយបន្ទាប់ពីអ្នកបានទទួលកុំព្យូទ័ររបស់អ្នក។ ដើម្បីចំមេរៀបម្រុងទុកនៃកម្មវិធីដែលអ្នកត្រូវការតំឡើងមុនពេលប្រើ Dell Factory Image Restore ។

ចំណាំ: Dell ធាចគៀរយ មីងារ៉ា អ្រុសគៀរ អាចនិងមីមានមានក្នុងប្រទេសមួយចំនួន ឬកុំព្យូទ័រមួយចំនួន ឡើយ។

ប្រើ Dell Factory Image Restore ជាវិធីចុងក្រោយដើម្បីស្តារ ប្រព័ន្ធប្រតិបត្តិការរបស់អ្នកឡើងវិញ។ ជម្រើសនេះស្តារស្ថូហ្គ័រនៅលើគ្រាយថាសរឹងរបស់អ្នកទៅលក្ខណៈដំបូងដែលវាបានចំពាក់មក។ កម្មវិធីឬឯកសារណាមួយដែលបានបន្ថែមបន្ទាប់ពីអ្នកបានទទួលកុំព្យូទ័ររបស់អ្នក – រួមទាំងឯកសារទិន្នន័យអូចជារូបភាព តន្ត្រីនិងវីដេអូ – ត្រូវបានលុបជាអចិន្ត្រៃយ៍។

ការប្រើ Dell Factory Image Restore

ប្រយ័ត្ន: ការប្រើនេះ នឹងលុបរាល់ទិន្នន័យនៅលើថាសរឹងទាំងអស់ និងលុបចោលនូវកម្មវិធី ឬ ក្រាយវើណា ដែលបានតម្លើងរួចហើយ ក្រោយពេលអ្នកបានទទួលកុំព្យូទ័ររបស់អ្នក។ ប្រសិនបើអាច ត្រូវចម្លងទិន្នន័យទុក មុនពេលប្រើ Dell Factory Image Restore។ ប្រើតែ Dell Factory Image Restore ប៉ុណ្ណោះ ប្រសិនបើវិធីសាស្ត្រស្តារឡើងវិញផ្សេងទៀតបរាជ័យ។

